លេខ៖ D292/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de réception): 19 / 08 / 2016
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

| | |
|---|---|
| ចំពោះមុខ ៖ | **សហចៅក្រមស៊ើបអង្កេត** |
| កាលបរិច្ឆេទ ៖ | **ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៦** |
| ភាសា ៖ | **អង់គ្លេស [ភាសាដើម]** |
| ចំណាត់ថ្នាក់ឯកសារ ៖ | **សម្ងាត់** |

# ដីកាសម្រេចលើសំណើរបស់ អោ អាន សុំឲ្យអង្គបុរេជំនុំជម្រះ ធ្វើមោឃភាពដីកាសម្រេច D193/55, D193/57, D193/59 និង D193/61

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**
មុំ លុង
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**
សូ មុស្សេទ្ធី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉េន ពៅ
Linda BEHNKE
Laure DESFORGES
NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

01320793



# I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

២. នៅថ្ងៃទី ៧, ១៦, ២១, ២៦ និង ៣០ ខែ តុលា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានស្នើសុំការអនុញ្ញាតពី ស.ច.ស ដាក់បង្ហាញឯកសារផ្សេងៗពីកិច្ចស៊ើបសួរ សំណុំរឿង ០០៤ ចូលក្នុងកិច្ចដំណើរការជំនុំជម្រះ និងបណ្តឹងសាទុក្ខសំណុំរឿង ០០២[1]។

៣. នៅថ្ងៃទី២០, ២៦ និង ២៨ ខែ តុលា និងថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ មេធាវីការពារក្តី អោ អាន("មេធាវីការពារក្តី") បានដាក់ចម្លើយតបទៅនឹងសំណើសុំដាក់បង្ហាញឯកសារខាងលើ[2]។ នៅក្នុងចម្លើយតបទី ១ និងទី ២ មេធាវីការពារក្តី បានស្នើថា ស.ច.ស គួរបដិសេធសំណើ សុំដាក់បង្ហាញឯកសារទាំងនេះ ឬក៏បង្គាប់ឱ្យ ស.ព.អ ត្រូវបង្ហាញកាលៈទេសៈពិសេសដែល

---

[1]សំណុំរឿង០០៤ ឯកសារ D193/45 *សំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៥។ សំណុំរឿង០០៤ ឯកសារ D193/46 *សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៥។ សំណុំរឿង០០៤ ឯកសារ D193/48 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥។ សំណុំរឿង០០៤ ឯកសារ D193/50 *សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៥។ សំណុំរឿង០០៤ ឯកសារ D193/52 *សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥។

[2]សំណុំរឿង០០៤ ឯកសារ D193/47 *ចម្លើយតបរបស់ អោ អាន ទៅនឹងសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៥។ សំណុំរឿង០០៤ ឯកសារ D193/49 *ចម្លើយតបរបស់ អោ អាន ទៅនឹងសំណើនានារបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារលេខ D193/46 និង D193/48 សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១៥។ សំណុំរឿង០០៤ ឯកសារ D193/51 *ចម្លើយតបរបស់ អោ អាន ទៅនឹងសំណើបន្ទាន់ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារលេខ D193/50 សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥។ សំណុំរឿង០០៤ ឯកសារ D193/53 *ចម្លើយតបរបស់ អោ អាន ទៅនឹងសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារលេខ D193/52 សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥។

01320794



តម្រូវឱ្យមានការដាក់បង្ហាញឯកសារនីមួយៗដែលបានស្នើ[3]។ នៅក្នុងចម្លើយតបទី ៣ និងទី ៤ មេធាវីការពារក្តី បានកត់សម្គាល់ថា ខ្លួននឹងមិនប្រឆាំងជាមួយនឹងការដាក់បង្ហាញឯកសារដែលបានស្នើឡើយ ដរាបណា ដីកាសម្រេចអនុញ្ញាតឱ្យដាក់បង្ហាញនេះធ្វើឡើងរួមគ្នាដោយ ស.ច.ស[4]។

៤. នៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ស.ព.អ បានដាក់ការឆ្លើយតបរួមទៅនឹងចម្លើយតបរបស់មេធាវីការពារក្តី[5]។

៥. នៅថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ខ្ញុំបានអនុញ្ញាតឱ្យដាក់បង្ហាញឯកសារដែល ស.ព.អ បានស្នើនៅក្នុងសំណើចុះថ្ងៃទី១៦ និង២៦ ខែតុលា ឆ្នាំ ២០១៥ ក្នុងចំណោមសំណើផ្សេងៗរបស់គាត់ ដោយឱ្យដាក់បង្ហាញឯកសារអាស្រ័យតាមការដាក់កំហិត និងទម្រង់បែបបទផ្សេងៗ ដើម្បីការពារសុចរិតភាពនៃកិច្ចស៊ើបសួរ ("ដីកាសម្រេច D193/55")[6]។

៦. នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ ២០១៥ មេធាវីការពារក្តី បានដាក់សំណើជូន ស.ច.ស ដោយស្នើសុំបញ្ជាក់បំភ្លឺថាតើ ខ្ញុំបានពិចារណាចម្លើយតបរបស់មេធាវីការពារក្តី ចុះថ្ងៃទី ២៦ និង ២៨ ខែ

---

[3]សំណុំរឿង០០៤ ឯកសារ D193/47 *ចម្លើយតបរបស់ អោ អាន ទៅនឹងសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ៥, ២៧, ២៨, ៤១, ៤៥ និង ៤៦។ សំណុំរឿង០០៤ ឯកសារ D193/49 *ចម្លើយតបរបស់ អោ អាន ទៅនឹងសំណើនានារបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារលេខ D193/46 និង D193/48 សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ៣,១២, ១៨, ១៩ និង ២០។

[4]សំណុំរឿង០០៤ ឯកសារ D193/51 *ចម្លើយតបរបស់ អោ អាន ទៅនឹងសំណើបន្ទាន់ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារលេខ D193/50 សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ២(ខ) និង ៣។ សំណុំរឿង០០៤ ឯកសារ D193/53 *ចម្លើយតបរបស់ អោ អាន ទៅនឹងសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារលេខ D193/52 សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ កថាខណ្ឌ ២(ខ) និង ៣។

[5]សំណុំរឿង០០៤ ឯកសារ D193/54 *ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ អោ អាន (D193/47, D193/49, D193/51 &D193/53) ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០១៥។

[6]សំណុំរឿង០០៤ ឯកសារ D193/55 *ដីកាសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារសំណុំរឿង ០០៤ ចូលក្នុងសំណុំរឿង ០០២/០១* ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០១៥។

តុលា ឆ្នាំ ២០១៥ ដែរឬអត់នៅពេលដែលចេញដីកាសម្រេច D193/55(“សំណើសុំការបញ្ជាក់បំភ្លឺ”)[7]។

៧. នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ខ្ញុំបានអនុញ្ញាតឱ្យដាក់បង្ហាញឯកសារដែល ស.ព.អ បានស្នើនៅក្នុងសំណើចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ដោយឱ្យដាក់បង្ហាញឯកសារអាស្រ័យតាមការដាក់កំហិត និងទម្រង់បែបបទផ្សេងៗដើម្បីការពារសុចរិតភាពនៃកិច្ចស៊ើបសួរ(“ដីកាសម្រេច D193/57”)[8]។

៨. នៅថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ ស.ព.អ បានដាក់សំណើមួយបន្ថែមទៀតសុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ចូលក្នុងកិច្ចដំណើរការជំនុំជម្រះសំណុំរឿង ០០២[9]។ នៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ ខ្ញុំបានអនុញ្ញាតឱ្យដាក់បង្ហាញឯកសារដែលបានស្នើ ដោយឱ្យដាក់បង្ហាញឯកសារអាស្រ័យតាមការដាក់កំហិត និងទម្រង់បែបបទផ្សេងៗ(“ដីកាសម្រេច D193/59”)[10]។

៩. នៅថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៥ មេធាវីការពារក្តី បានដាក់ចម្លើយតបទៅនឹងសំណើសុំដាក់បង្ហាញឯកសាររបស់ ស.ព.អ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ ដោយលើកឡើងម្តងទៀតនូវសំណើរបស់ខ្លួនដែលស្នើថា ដីកាសម្រេចទាំងអស់ទាក់ទងនឹងការដាក់បង្ហាញឯកសារគួរចេញរួមគ្នាដោយ ស.ច.ស[11]។ ចម្លើយតបនេះបានដាក់ទោះបីជាថា ដីកាសម្រេច D193/59 បានចេញរួចក៏ដោយ ប៉ុន្តែ ខ្ញុំយល់ឃើញថា មេធាវីការពារក្តី ប្រហែលជាមិនបានដឹងអំពីដីកា

---

[7]សំណុំរឿង០០៤ ឯកសារ D193/56 *សំណើសុំការបញ្ជាក់ចំពោះសេចក្តីសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារនៃសំណើរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២/០១* ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១៥។

[8]សំណុំរឿង០០៤ ឯកសារ D193/57 *ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ D193/52* ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១៥។

[9]សំណុំរឿង០០៤ ឯកសារ D193/58 *សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០១៥។

[10]សំណុំរឿង០០៤ ឯកសារ D193/59 *ដីកាសម្រេចលើសំណើបន្ទាន់ D193/58 របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារ* ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ២០១៥។

[11]សំណុំរឿង០០៤ ឯកសារ D193/60 *ចម្លើយតបរបស់ អោ អាន ទៅនឹងសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារលេខ D193/58 សុំដាក់បង្ហាញឯកសារសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ២។

សម្រេចនេះនៅដំណាក់កាលនោះ ដោយពិនិត្យឃើញថា ដីកាសម្រេចនេះ ដូចគ្នានឹងដីកាសម្រេចដាក់បង្ហាញឯកសារពីមុនៗដែរ គឺមិនបានផ្ញើជូនក្រុមមេធាវីការពារក្តី ឬដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤ ឡើយ។

១០. នៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៥ ខ្ញុំបានអនុញ្ញាតឱ្យដាក់បង្ហាញឯកសារដែល ស.ព.អ បានស្នើនៅក្នុងសំណើចុះថ្ងៃទី ០៧ និង ២១ ខែ តុលា ឆ្នាំ ២០១៥ ក្នុងចំណោមសំណើផ្សេងៗរបស់គាត់(“ដីកាសម្រេច D193/61”)[12]។

១១. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ខ្ញុំបានចេញដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ ដែលនៅក្នុងដីកាសម្រេចនេះ ខ្ញុំបានបញ្ជាក់ថា ទឡ្ហីករណ៍ដែលបានបង្ហាញនៅក្នុងចម្លើយតបផ្សេងៗរបស់មេធាវីការពារក្តី ត្រូវបានពិចារណានៅពេលដែលចេញដីកាសម្រេច D193/55 ហើយក្នុងករណីណាក៏ដោយ ក៏ខ្ញុំមិនជាប់កាតព្វកិច្ចត្រូវដោះស្រាយឱ្យបានច្បាស់ចំពោះគ្រប់ទឡ្ហីករណ៍របស់ភាគី អំពីបញ្ហាច្បាប់ណាមួយនៅពេលដែលធ្វើសេចក្តីសម្រេចឡើយ (“ដីកាសម្រេចអំពីការបញ្ជាក់បំភ្លឺ”)[13]។

១២. នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៦ មេធាវីការពារក្តី បានប្តឹងឧទ្ធរណ៍ជំទាស់នឹង ដីកាសម្រេចអំពីការបញ្ជាក់បំភ្លឺ ទៅអង្គបុរេជំនុំជម្រះ (“អ.ប.ជ”) ដោយស្នើ អ.ប.ជ សុំច្រានចោលដីកាសម្រេចនេះ ហើយបង្គាប់ឱ្យខ្ញុំ លុបចោលដីកាបង្គាប់ និងដីកាសម្រេចពីមុនៗទាំងអស់ទាក់ទងនឹងការដាក់បង្ហាញឯកសារសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២ (“បណ្តឹងឧទ្ធរណ៍”)[14]។

---

[12]សំណុំរឿង០០៤ ឯកសារ D193/61 *ដីកាសម្រេចលើសំណើ D193/29, D193/35, D193/38, D193/39, D193/42, D193/45, D193/46 និង D193/48 របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារ* ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥។

[13]សំណុំរឿង០០៤ ឯកសារ D284 *ដីកាសម្រេចលើចម្លើយតបរបស់ អោ អាន D19/47, D193/49, D193/51, D193/53, D193/56 និង D193/60* ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ២៣។

[14]សំណុំរឿង០០៤ ឯកសារ D284/1/2 *បណ្តឹងឧទ្ធរណ៍របស់ អោ អាន ជំទាស់ទៅនឹងដីកាសម្រេចលើចម្លើយតបឯកសារ D19/47, D193/49, D193/51, D193/53, D193/56 និង D193/60* ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០១៦ កថាខណ្ឌ ៧៨។

១៣. នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ អ.ប.ជ បានច្រានចោលបណ្ដឹងឧទ្ធរណ៍ ថាមិនអាចទទួលយកបានឡើយ[15]។

១៤. នៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៦ មេធាវីការពារក្ដី បានដាក់សំណើជូនទៅ ស.ច.ស សុំឱ្យអង្គបុរេជំនុំជម្រះ ធ្វើមោឃភាពដីកាសម្រេច D193/55, D193/57, D193/59 និង D193/61 ("សំណើ")[16]។

## II. សារណា

១៥. មេធាវីការពារក្ដី អះអាងថា ដីកាសម្រេច D193/55, D193/57, D193/59 និង D193/61 (ហៅកាត់រួមថា "ដីកាសម្រេចដាក់បង្ហាញឯកសារ") មានកំហុសនីតិវិធី យោងតាមវិធានផ្ទៃក្នុង ៤៨ ត្រង់ពីរចំណុច។ ទី១ មេធាវីការពារក្ដី មិនត្រូវបាន ជូនដំណឹងអំពីដីកាសម្រេចដាក់បង្ហាញឯកសារ គឺផ្ទុយពីលក្ខខណ្ឌតម្រូវនៅវិធានផ្ទៃក្នុង ៥៦[17]។ ទី ២ ដីកាសម្រេចដាក់បង្ហាញឯកសារ មិនបានទទួលស្គាល់ការដាក់ឯកសារពាក់ព័ន្ធរបស់មេធាវីការពារក្ដី ឬក៏មិនបានដោះស្រាយទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងឯកសារទាំងនោះ[18]។ មេធាវីការពារក្ដីសន្និដ្ឋានថា ការមិនបានទទួលស្គាល់នេះគឺដោយសារថា នៅត្រង់ផ្នែក"ប្រវត្តិនីតិវិធី" និង "សារណា"នៃដីកាសម្រេចដាក់បង្ហាញឯកសារ មិនបានលើកយោងឱ្យបានគ្រប់គ្រាន់អំពីចម្លើយតបរបស់មេធាវីការពារក្ដី ទាក់ទងនឹងការដាក់បង្ហាញឯកសារ[19]។ មេធាវីការពារក្ដី អះអាងថា បញ្ហានេះរំលោភបំពានសិទ្ធិរបស់ អោ អាន ក្នុងការទទួលបានសេចក្ដីសម្រេចដែលមានសំអាងហេតុ និងសិទ្ធិធ្វើសារណាជាលាយលក្ខណ៍អក្សរ យោងតាមវិធានផ្ទៃក្នុង ៥៦(២) និង ៩២[20]។

---

[15] សំណុំរឿង00៤ ឯកសារ D284/1/4 *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អោ អាន ជំទាស់ទៅនឹងដីកាសម្រេចលើចម្លើយតបឯកសារ D193/47, D193/49, D193/51, D193/53, D193/56 និង D193/60* ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១៦។

[16] សំណុំរឿង00៤ ឯកសារ D292 *សំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពដីកាសម្រេច ឯកសារ D193/55, D193/57, D193/59 និង D193/61* ថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៦។

[17] សំណើ កថាខណ្ឌ ២, ៣៩ និង ៤២។

[18] សំណើ កថាខណ្ឌ ២ និង ៣៩។

[19] សំណើ កថាខណ្ឌ ៤៤។

[20] សំណើ កថាខណ្ឌ ៤៥ និង ៤៦។

១៦. មេធាវីការពារក្តី អះអាងថា កំហុសទាំងនេះរំលោភបំពានសិទ្ធិជាមូលដ្ឋានរបស់ អោ អាន នៅវិធានផ្ទៃក្នុង ២១ ជាពិសេស សិទ្ធិរបស់គាត់ ក្នុងការប្តឹងឧទ្ធរណ៍ សិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុ សិទ្ធិទទួលបានសមភាពនៅចំពោះមុខតុលាការ សិទ្ធិទទួលបានសមភាពនៃមធ្យោបាយតទល់ក្តី និងសិទ្ធិចូលរួមប្រកបដោយប្រសិទ្ធភាព[21]។ មេធាវីការពារក្តី អះអាងថា ការរំលោភបំពានកើនឡើងជាន់គ្នាទាំងនេះគឺជាការរំលោភបំពានសិទ្ធិរបស់ អោ អាន ក្នុងការទទួលបានសុចរិតភាពនៃកិច្ចស៊ើបសួរ ដែលការរក្សាសុចរិតភាពនេះគឺជាការទទួលខុសត្រូវជាចម្បងរបស់ ស.ច.ស[22]។

១៧. យោងតាមវិធានផ្ទៃក្នុង ៧៦(២) មេធាវីការពារក្តី ស្នើ ស.ច.ស សុំឱ្យប្តឹងទៅ អ.ប.ជ ដើម្បីធ្វើមោឃភាពដីកាសម្រេចដាក់បង្ហាញឯកសារ[23]។

## III. ពិភាក្សា

១៨. នៅពេលដែលទទួលពិនិត្យពាក្យសុំដែលបានដាក់តាមវិធានផ្ទៃក្នុង ៧៦(២) ស.ច.ស ចាំបាច់ត្រូវជឿជាក់ថា ពាក្យសុំនោះមានសំអាងហេតុដែលបញ្ជាក់ថា (i) មានករណីមិនគោរពវិធានបញ្ញត្តិ[កំហុសនីតិវិធី] និង (ii) កំហុសបែបនោះរំលោភសិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំ[24]។ លក្ខខណ្ឌនេះតម្រូវឱ្យមានសេចក្តីសម្រេចថា អ្នកដាក់ពាក្យសុំ មាន"ករណីដែលអាចជំទាស់តវ៉ាបាន" ប៉ុន្តែ មិនអនុញ្ញាតឱ្យត្រួតពិនិត្យមើលអង្គសេចក្តីនៃពាក្យសុំឡើយ[25]។

---

[21]សំណើ កថាខណ្ឌ ៣, ៣៩,៥១,៥២, ៥៥ និង ៥៧។

[22]សំណើ កថាខណ្ឌ ៦០។

[23]សំណើ កថាខណ្ឌ ៤, ៦៣ និង ៦៥។

[24]សំណុំរឿង០០២ ឯកសារ D263/2/6 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1)* ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១០ កថាខណ្ឌ ១៨។ សំណុំរឿង០០៣ ឯកសារ D134/1/10 *សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ [កោសលុប] ប្រឆាំងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់ [កោសលុប]ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ* ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ១៩។

[25]ដូចជើងទំព័រខាងលើ។

១៩. អ.ប.ជ បានបញ្ជាក់ថែមទៀតនាពេលថ្មីៗនេះអំពីតួនាទីរបស់ ស.ច.ស ក្នុងការវាយតម្លៃពាក្យសុំយោងតាមវិធានផ្ទៃក្នុង ៧៦(២) ដោយបញ្ជាក់ថា ស.ច.ស គ្រាន់តែចាំបាច់ត្រូវជឿជាក់ថា *"ពាក្យសុំមានហេតុផលគ្រប់គ្រាន់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយត្រូវបង្ហាញអំពីកំហុសនីតិវិធីដែលចោទប្រកាន់ និងការខូចខាត ប្រសិនបើមាន ដែលជនត្រូវចោទបានទទួលរង ដោយសារតែកំហុសនីតិវិធីនោះ"* [26]។ ខ្ញុំនឹងវាយតម្លៃសំណើ ដោយស្របតាមសេចក្ដីណែនាំបន្ថែមនេះ។

## ក. កំហុសនីតិវិធីទី ១ ដែលចោទថាមិនបានជូនដំណឹង និងមិនបានផ្ញើជូនដីកាសម្រេចដាក់បង្ហាញឯកសារ ទៅមេធាវីការពារក្ដី

២០. មេធាវីការពារក្ដី កំណត់ថា ការខកខានរបស់ ស.ច.ស ដែលមិនបានផ្ញើ និងជូនដំណឹងមេធាវីការពារក្ដីអំពីដីកាសម្រេចដាក់បង្ហាញឯកសារ គឺជាកំហុសនីតិវិធី ដោយផ្អែកលើមូលដ្ឋានថា ការខកខាននេះផ្ទុយពីវិធានផ្ទៃក្នុង ៤៦។ មេធាវីការពារក្ដី ផ្ដល់ទឡ្ហីករណ៍ថា កំហុសនេះប៉ះពាល់លទ្ធភាពរបស់ខ្លួនក្នុងការប្រើប្រាស់សិទ្ធិរបស់ អោ អាន ក្នុងការប្ដឹងឧទ្ធរណ៍ ដោយសាររារាំង មេធាវីការពារក្ដី មិនឱ្យបានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍តាមពេលវេលាកំណត់តាមវិធានជាធរមាន[27]។ ការមិនបានជូនដំណឹងឱ្យបានគ្រប់គ្រាន់ គឺប៉ះពាល់សិទ្ធិរបស់ អោ អាន ក្នុងការទទួលបានសមភាពនៃមធ្យោបាយតទល់ក្ដីនៅក្នុងកាលៈទេសៈដែល ស.ព.អ ទទួលបានសេចក្ដីជូនដំណឹងអំពីដីកាសម្រេចដាក់បង្ហាញឯកសារ ហេតុនេះ ស.ព.អ អាចប្រើប្រាស់សិទ្ធិនីតិវិធីទាំងអស់របស់គាត់ ខណៈដែល អោ អាន មិនអាចប្រើប្រាស់សិទ្ធិបែបនេះបានឡើយ[28]។

២១. ខ្ញុំជឿជាក់ថា មេធាវីការពារក្ដី មានទឡ្ហីករណ៍ដែលមានសំអាងហេតុដើម្បីគាំទ្រកំហុសនីវិធីដែលបានចោទ និងផលប៉ះពាល់បណ្ដាលមកពីកំហុសនេះ។ ប៉ុន្តែ សេចក្ដីសន្និដ្ឋានអំពីអង្គហេតុនៃកំហុសនីតិវិធីនេះគឺសមហេតុផលចំពោះដីកាសម្រេចដាក់បង្ហាញឯកសារទាំង

---

[26] សំណុំរឿង០០៣ ឯកសារ D134/1/10 *សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍របស់ [កោសលុប] ប្រឆាំងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់[កោសលុប]ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ* ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ២០។

[27] សំណើ កថាខណ្ឌ ៩៩។

[28] សំណើ កថាខណ្ឌ ៥៥។

01320800



អស់ លើកលែងតែដីកាសម្រេចមួយចេញ៖ ផ្ទុយពីការអះអាងរបស់មេធាវីការពារក្ដី សហមេធាវីរបស់ អោ អាន គឺលោក មុំ លុជ្ជ លោក Richard ROGERS និងលោក Göran SLUITER តាមពិតត្រូវបានជូនដំណឹងអំពីដីកាសម្រេច D193/55 នៅថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ រួមជាមួយនឹងភាគីផ្សេងទៀតទាំងអស់នៅក្នុងសំណុំរឿង ០០៤ ដូចបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ក ភ្ជាប់ជាមួយនឹងដីកាសម្រេចនេះ។ ហេតុនេះ ការអះអាងថា ដីកាសម្រេច D193/55 មានកំហុសដោយសារមិនបានជូនដំណឹង និងមិនបានផ្ញើជូនដីកាសម្រេចនោះទៅមេធាវីការពារក្ដី គឺជាការអះអាងដែលមិនអាចទទួលយកបាន។

២២. ជាមតិយោបល់ទូទៅអំពីបញ្ហាការជូនដំណឹង និងការផ្ញើជូនដីកាសម្រេចដាក់បង្ហាញឯកសារ គឺដូចបានបញ្ជាក់ពីមុនរួចហើយនៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦[29] ខ្ញុំបញ្ជាក់ថា ដីកាសម្រេចដាក់បង្ហាញឯកសារទាំងអស់នាពេលខាងមុខ នឹងត្រូវជូនដំណឹង និងផ្ញើជូនភាគីទាំងអស់នៅក្នុងសំណុំរឿង ០០៤ មិនត្រឹមតែសហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះពាក់ព័ន្ធ ដូចបានអនុវត្តកន្លងមកនោះឡើយ។

**ខ. កំហុសនីតិវិធីទី ២ ដែលចោទថាមិនបានទទួលស្គាល់ចម្លើយតបរបស់មេធាវីការពារក្ដី**

២៣. កំហុសនីតិវិធីទី ២ ដែលមេធាវីការពារក្ដី បានបង្ហាញ គឺការមិនបានទទួលស្គាល់ទឡ្ហីករណ៍របស់មេធាវីការពារក្ដី នៅក្នុងចម្លើយតបទៅនឹងសំណើសុំដាក់បង្ហាញឯកសាររបស់ ស.ព.អ នៅពេលដែលចេញដីកាសម្រេចដាក់បង្ហាញឯកសារ។ កំហុសនេះបានចោទថាធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ អោ អាន ក្នុងការទទួលបានសេចក្ដីសម្រេចដែលមានសំអាងហេតុ ហេតុនេះប៉ះពាល់សិទ្ធិរបស់គាត់ក្នុងការប្ដឹងឧទ្ធរណ៍ និងធ្វើឱ្យគាត់មិនអាចប្រើប្រាស់សិទ្ធិធ្វើសារណាជាលាយលក្ខណ៍អក្សរយោងតាមវិធានផ្ទៃក្នុង ៥៦(២) និង ៩២[30]។ ចុងក្រោយបង្អស់ មេធាវីការពារក្ដី អះអាងថា កំហុសកើនឡើងជាន់គ្នាទាំងនេះបានរំលោភបំពានសុចរិតភាពនៃកិច្ចស៊ើបសួរ[31]។

---

[29]សំណុំរឿង០០៤ ឯកសារ D193/74 *ដីកាសម្រេចលើសំណើបន្ទាន់របស់ យឹម ទិត្យ សុំផ្អាកការអនុវត្តដីកាសម្រេច D193/69* ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០១៦ កថាខណ្ឌ ១៥។

[30]សំណើ កថាខណ្ឌ ៤៦, ៥០ និង ៥២។

[31]សំណើ កថាខណ្ឌ ៦០។

01320801



២៤. នៅក្នុងដីកាសម្រេចអំពីការបញ្ចាក់បំភ្លឺ ខ្ញុំបានបញ្ជាក់ថា ខ្ញុំបានពិចារណាទឡ្ហីករណ៍ដែលមេធាវីការពារក្តីបានលើកឡើងនៅក្នុងចម្លើយតបរបស់ខ្លួនទាក់ទងនឹងការដាក់បង្ហាញឯកសារនៅពេលដែលចេញដីកាសម្រេច D193/55 ហើយខ្ញុំមិនជាប់កាតព្វកិច្ចត្រូវដោះស្រាយឱ្យបានច្បាស់ចំពោះគ្រប់ទឡ្ហីករណ៍របស់ភាគីអំពីបញ្ហាច្បាប់ឡើយនៅពេលដែលចេញសេចក្តីសម្រេច[32]។ ខ្ញុំក៏បានបង្ហាញការយល់ឃើញរបស់ខ្ញុំ ដើម្បីឆ្លើយតបទៅនឹងទឡ្ហីរណ៍ផ្សេងៗ ដែលមេធាវីការពារក្តី បានលើកឡើងនៅក្នុងចម្លើយតបរបស់ខ្លួនទាក់ទងនឹងការដាក់បង្ហាញឯកសារ។ មេធាវីការពារក្តី បានប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចអំពីការបញ្ជាក់បំភ្លឺ ប៉ុន្តែតែត្រង់ចំណុចពាក់ព័ន្ធនឹងការយល់ឃើញរបស់ខ្ញុំ ដែលឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់មេធាវីការពារក្តី អំពីការដាក់បង្ហាញឯកសារតែប៉ុណ្ណោះ។ បណ្តឹងឧទ្ធរណ៍នេះមិនបានពាក់ព័ន្ធនឹងបញ្ហាចោទថាតើ ដីកាសម្រេចដាក់បង្ហាញឯកសារ គឺជាដីកាសម្រេចដែលមានសំអាងហេតុដែរឬអត់នោះទេ ជាដីកាសម្រេចដែលបានពិចារណាទឡ្ហីករណ៍របស់មេធាវីការពារក្តីអំពីការដាក់បង្ហាញឯកសារ។ អ.ប.ជ បានសម្រេចថា បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន[33] ហេតុនេះ អ.ប.ជ មិនបានសម្រេចលើអង្គសេចក្តីនៃបណ្តឹងនេះឡើយ។ អ.ប.ជ បានរកឃើញថាមិនមានអង្គសេចក្តីនៅក្នុងទឡ្ហីករណ៍របស់ អោ អាន ដែលថា មាត្រា ៨៣ និង ១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ផ្តល់ជូនគាត់នូវសិទ្ធិមានជាប់រួចជាស្រេចក្នុងការទទួលបានសុចរិតភាពនៅក្នុងការបំពេញកិច្ចស៊ើបសួរ សិទ្ធិទទួលបានកិច្ចស៊ើបសួរដោយសម្ងាត់ ឬសិទ្ធិការពារកេរ្តិ៍ឈ្មោះរបស់គាត់ឡើយ[34] ប៉ុន្តែ អ.ប.ជ មិនបានពិចារណាថាតើសិទ្ធិផ្សេងទៀតដែលបានបង្ហាញខាងលើនៅត្រង់កថាខណ្ឌ ២៣ បានទទួលរងផលប៉ះពាល់យ៉ាងណាដោយសារដីកាសម្រេចដាក់បង្ហាញឯកសារឡើយ ហើយ អ.ប.ជ ក៏មិនបានទទួលសំណើសុំឱ្យធ្វើការពិចារណាបែបនោះដែរ។

---

[32]ដីកាសម្រេចអំពីការបញ្ជាក់បំភ្លឺ កថាខណ្ឌ ២៣។

[33]សំណុំរឿង០០៤ ឯកសារ D284/1/4 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អោ អាន ជំទាស់ទៅនឹងដីកាសម្រេចលើចម្លើយតបឯកសារ D193/47, D193/49, D193/51, D193/53, D193/56 និង D193/60* ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១៦។

[34]សំណុំរឿង០០៤ ឯកសារ D284/1/4 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អោ អាន ជំទាស់ទៅនឹងដីកាសម្រេចលើចម្លើយតបឯកសារ D193/47, D193/49, D193/51, D193/53, D193/56 និង D193/60* ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១៦ កថាខណ្ឌ ២៣។

២៥. នៅក្នុងកាលៈទេសៈនេះ ខ្ញុំជឿជាក់ថា មេធាវីការពារក្តី មានករណីដែលអាចជំទាស់តវ៉ាបាន ចំពោះកំហុសនីតិវិធីទី ២ ដែលបានចោទទាក់ទនឹងដីកាសម្រេចដាក់បង្ហាញឯកសារទាំងអស់( គឺដីកាសម្រេច D193/55, D193/57, D193/59 និង D193/61)។

**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

២៦. **អនុញ្ញាតតាម** សំណើ។

២៧. **បង្គាប់** ក្រឡាបញ្ជីរបស់ ក.ស.ច.ស ត្រូវបញ្ជូនសំណុំរឿង ០០៤ ជូនទៅអង្គបុរេជំនុំជម្រះ យោងតាមវិធានផ្ទៃក្នុង ៧៦(៣)។

ភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**